# ទស្សនាវដ្តី ព្រៃឈើ



រដ្ឋបាលព្រៃឈើ

ឧសភា ២០២២

៦៥

# មាតិកាអត្ថបទ

**ល.រ ឈ្មោះអត្ថបទ** **ទំព័រ**


១- សមិទ្ធផលការងារប្រចាំឆ្នាំ២០២១ របស់រដ្ឋបាលព្រៃឈើ ....................១

២- ការពិសោធន៍ឥទ្ធិពលអ័រម៉ូនលើការដុះលូតលាស់ប្រព័ន្ធឫសរបស់អាកាស្យា និងប្រេងខ្យល់ ....................២២

៣- សិក្សាលើការដុះលូតលាស់ និងការឆ្លើយតបនៃរូបសាស្ត្រ និងសរីរៈរបស់កូនឈើគ្រញូងទៅនឹងកំណើននៃឧស្ម័នកាបូនិច ...២៦

៤- ក្រខុបព្រៃ....................៣៧

៥- ការចែករំលែកបទពិសោធន៍ជាក់ស្តែងរបស់កសិករគំរូក្រោមប្រធានបទ "ចំណាយពេលវេលាតិច និងទទួលបានផលចំណេញច្រើន" គាំទ្រដោយគម្រោងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេដបូកក្នុងខេត្តកំពង់ធំ (ITTO PD740/14 Rev.2(F)) ....................៣៩

៦- ស្វែងយល់ពី ដើមគ្រញូងហៃណាន ....................៤២

៧- ការអភិរក្សសត្វព្រៃនៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ ....................៤៧

៨- ស្វែងយល់ពី សត្វតោ ....................៤៩

៩- ការអនុវត្តការងារដោះលែងសត្វព្រៃ ....................៥៤

១០- ការអភិរក្សសត្វខ្សឹបនៅប្រទេសកម្ពុជា....................៥៦

១១- ការសិក្សាស្រាវជ្រាវសត្វព្រៃក្នុងតំបន់សហគមន៍ព្រៃឈើវាលកន្សែង ស្រុកឆ្លូង ខេត្តក្រចេះ....................៦០

១២- ស្វែងយល់ពី សត្វប្រវឹក ....................៦៥

១៣- កម្សាន្ត ....................៦៨

១៤- កំណាព្យ “ កង្វល់ម្រឹគព្រៃ ” (តចប់) ....................៦៩



យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានជួយឧបត្ថម្ភ ផ្តល់នូវអត្ថបទ និងរូបភាពសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីរបស់យើងខ្ញុំៗ **ទន្ទឹមនឹងនេះ** យើងខ្ញុំសូមអំពាវនាវដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមមេត្តាជួយជ្រោមជ្រែង ផ្តល់នូវមតិរិះគន់ស្ថាបនា ផ្តល់អត្ថបទមានអត្ថប្រយោជន៍ផ្សេងៗដើម្បីចុះផ្សាយក្នុងទស្សនាវដ្តីជាបន្តបន្ទាប់ទៀតៗ *(ទំនាក់ទំនងព័ត៌មាន-ផ្តល់អត្ថបទ* ***077 98 17 98*** *(Telegram))*

*សូមអរគុណ!*

***រដ្ឋបាលព្រៃឈើ***





អគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ (កម្ពុជា)

E-mail : tech6777@gmail.com

Website: https://fa.maff.gov.kh




# សមិទ្ធផលការងារ ប្រចាំឆ្នាំ២០២១ របស់រដ្ឋបាលព្រៃឈើ

យុទ្ធសាស្ត្រក្នុងការកែទម្រង់វិស័យព្រៃឈើ គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមជាមួយប្រព័ន្ធការពារធនធានធម្មជាតិ និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើប្រកបដោយប្រសិទ្ធភាពសំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម កាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្តៅនៃភពផែនដី។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋបាលព្រៃឈើ ដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូអភិវឌ្ឍន៍នានា បំពេញតួនាទីភារកិច្ចទៅតាមអាណត្តិរបស់ខ្លួន ដោយសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

## ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

ក្នុងឆ្នាំ២០២១នេះ រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់បានសហការជាមួយកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ក្នុងទូទាំងប្រទេសធ្វើការបង្ក្រាបបទល្មើសព្រៃឈើ-សត្វព្រៃនិងបទល្មើសកាប់រានដីព្រៃ ទទួលបាននូវសមិទ្ធផលដូចខាងក្រោម៖

-សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើ សរុបចំនួន៨១១ករណី(ព្រៃឈើចំនួន៦៣៤ករណី សត្វព្រៃចំនួន៣១ករណី និងកាប់រានដីព្រៃចំនួន១៤៦ករណី)ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន **៣២០ករណី** និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន**៤៩១ករណី**

-វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើអារសរុបចំនួន**១២៦០**ម៉ែត្រគ្រីគុណ (ចំនួន៦៣៤ករណី) ឈើមូល-ជ្រុងសរុបចំនួន **៣២**ម៉ែត្រគ្រីគុណ ឈើអារគ្រាក់គ្រញូង **០**ម៉ែត្រគ្រីគុណ**៧៧១** និង **៨៦០**គីឡូក្រាម

-ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ **១៦៣៩៣**ហិកតា (ចំនួន១៤៦ករណី៖ ខេត្តព្រៃវែង ០៥ករណី ក្រចេះ ៣៧ករណី ព្រះវិហារ ៣៧ករណី ស្ទឹងត្រែង ០៨ករណី រតនគិរី ០៧ករណី មណ្ឌលគិរី០១ករណី កំពង់ធំ១៤ករណី សៀមរាប០៣ករណី បាត់ដំបង០៤ករណី តាកែវ០៧ករណី កំពង់ស្ពឺ០៥ករណី ព្រះសីហនុ០១ករណី និងខេត្តកំពង់ឆ្នាំង១៧ករណី)

-វត្ថុតាងសត្វព្រៃដែលបានចាប់ឃាត់ទុកមានចំនួន ២០២០ក្បាល និង៥៩៦គីឡូក្រាម (ចំនួន៣១ករណី ខេត្តក្រចេះ ចំនួន០១ករណី ខេត្តព្រះសីហនុចំនួន០២ករណី ខេត្តសៀមរាប ចំនួន០៣ករណី ខេត្តកំពង់ធំ ០១ករណី រាជធានីភ្នំពេញ ០១ករណី ខេត្តកណ្តាល ០១ករណី និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើ ចំនួន ២២ករណី និងអនុផលព្រៃឈើព្រមទាំងឧបករណ៍ សម្ភារផ្សេងៗមួយចំនួនទៀត

-វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃបានប្រមូលតាមរយៈការប្រគល់-ទទួលចំនួន៣៧៧ករណី ធ្វើកិច្ចសន្យា ៥៦ករណី និងដកហូត៦៤ករណី រួមមាន៖សត្វព្រៃរស់ចម្រុះប្រភេទចំនួន១០១៦ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន ៣០២៥ក្បាល និង៨៥,៦០គីឡូក្រាម ចែជ្រូកព្រៃចំនួន០៣ ទ្រូងអណ្តើកស្រែចំនួន១៩ ទ្រូងអណ្តើកភ្នំចំនួន១១ ទ្រូងអណ្តើកសោមចំនួន០១ស្នូកអណ្តើកភ្នំចំនួន០៥ ស្នូកអណ្តើកស្រែចំនួន០២ ត្រចៀកទន្សាយក្រៀមចំនួន០៥គូ កន្ទុយទន្សាយក្រៀមចំនួន១១កន្ទុយ និងក្រចកខ្លាឃ្មុំចំនួន០២។

-បានស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យព្រៃឈើក្នុងបណ្តាញសារព័ត៌មាននានាបានចំនួន **១៩៧**ករណី ដោយអត្ថបទសារព័ត៌មានទាំងនេះ និងដីព្រៃឈើទាំងអស់ត្រូវបានរក្សាទុកជាឯកសារ និងបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រព្រមទាំងផ្ទៀងផ្ទាត់ឲ្យមានសុក្រឹតភាព។





រដ្ឋបាលព្រៃឈើទទួលរថយន្ត១គ្រឿង ដែលដឹកជញ្ជូនឈើអារល្មើសច្បាប់ប្រភេទប្រណីត(បេង ធ្នង់) ពីកងកម្លាំងរាជអាវុធហត្ថ
ក្រុងព្រះវិហារ ក្នុងភូមិសាស្ត្រ ភូមិដំណាក់ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ នាថ្ងៃទី២៩-០៩-២០២១





ចាប់ឃាត់រថយន្ត១គ្រឿង ដែលដឹកជញ្ជូនឈើអារល្មើសច្បាប់ប្រភេទប្រណីត(នាងនួន) និងប្រភេទលេខ១(ធ្នឹក)
ក្នុងភូមិសាស្ត្រ ភូមិកៅ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល នាថ្ងៃទី១៣-០៨-២០២១





ចាប់ឃាត់រថយន្ត១គ្រឿង ដែលដឹកជញ្ជូនឈើអារល្មើសច្បាប់ប្រភេទលេខ១
ក្នុងភូមិសាស្ត្រ ភូមិខ្ទាំង ឃុំរីករាយ ស្រុករវៀង ខេត្តព្រះវិហារ នាថ្ងៃទី១៧-០៩-២០២១

# សមិទ្ធផលការងារគ្រប់គ្រងព្រៃឈើ និង សហគមន៍ព្រៃឈើ

## ១-ការវាយតម្លៃគម្របព្រៃឈើ

-បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ បានចំនួន ៣០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 បានចំនួន ២៥ផ្ទាំង

-បាន និងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១ សរុបបាន ៥០%

-បានពង្រឹងសមត្ថភាពមន្ត្រី លើជំនាញបច្ចេកទេស Google earth engine, GPS, Avenza និងកំពុងរៀបចំផែនទី PDF សម្រាប់ប្រើប្រាស់ក្នុង Avenza តាមបណ្ដាផ្នែករដ្ឋបាលព្រៃឈើនីមួយៗ សរុបចំនួន ៧០%



កិច្ចប្រជុំស្ដីពីការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តកំពង់ធំ



ការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តកំពង់ធំ

-បានចុះប្រមូលព័ត៌មាននៅទីវាលជាក់ស្ដែងតាមចំណុចនិយាមកា ដែលបានធ្វើការចាត់ថ្នាក់រួចតាមរូបភាពផ្កាយរណប ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់បានចំនួន ២៨៤ចំណុច ក្នុងខេត្តចំនួន ០៤ខេត្ត គឺខេត្តកំពង់ធំ ១០២ចំណុច ពោធិ៍សាត់ ៤២ចំណុច សៀមរាប ៩១ចំណុច និងខេត្តបាត់ដំបង ៤៩ចំណុច។

## ២-សហគមន៍ព្រៃឈើ

### ២.១-ការបង្កើត និងការចុះកិច្ចព្រមព្រៀង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្ដីប្រកាសស្ដីពីការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍ចំនួន ០៧កន្លែង មានផ្ទៃដីសរុបទំហំ ៣ ៦៧៣,៧៨ ហិកតា រួមមាន៖

-ព្រៃសហគមន៍រយាស ផ្ទៃដីទំហំ ២៨៤,៨៦ហិកតា និងព្រៃសហគមន៍ខ្សាច់ពូន ផ្ទៃដីទំហំ ៣៩៣ហិកតា ស្ថិតនៅខេត្តកំពង់ឆ្នាំង

-ព្រៃសហគមន៍ភូមិវាលវង់ ផ្ទៃដីទំហំ២ ៥៦៧ហិកតា ព្រៃសហគមន៍អូរអាចម៍កុក ផ្ទៃដីទំហំ ១២២ហិកតា ស្ថិតនៅខេត្តពោធិ៍សាត់

-ព្រៃសហគមន៍ប្រាំបីមុមពីរ ផ្ទៃដីទំហំ ២៥៣ហិកតា ស្ថិតនៅខេត្តកំពង់ស្ពឺ

-ព្រៃសហគមន៍ភ្នំព្រិច ផ្ទៃដីសរុបទំហំ ៣៥ហិកតា និងព្រៃសហគមន៍ភ្នំត្នោត ផ្ទៃដីសរុបទំហំ ១៨,៩២ហិកតា ស្ថិតនៅខេត្តក្រចេះ។



កិច្ចប្រជុំផ្សព្វផ្សាយស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើដល់សមាជិកសហគមន៍ព្រៃឈើភូមិប្រស្និប និងសហគមន៍ព្រៃឈើភូមិត្រពាំងអំពិល ស្ថិតនៅខេត្តកំពង់ឆ្នាំង

## ២.២-ការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍

បានទទួលសេចក្តីយល់ព្រមជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន០៦កន្លែង មានផ្ទៃដីសរុបទំហំ ៣ ៦៣៧ហិកតា រួមមាន៖

-សហគមន៍ព្រៃឈើប្រា ផ្ទៃដីសរុបទំហំ ៣៦៩ហិកតា សហគមន៍ព្រៃឈើគុណភាព ផ្ទៃដីសរុបទំហំ៣៩៤ហិកតា និងសហគមន៍ព្រៃឈើភ្នំដែកចំបក់ហោះ ផ្ទៃដីសរុបទំហំ ៨៦៧ហិកតា ស្ថិតនៅក្នុងខេត្តព្រះវិហារ

-សហគមន៍ព្រៃឈើស្រែធំ ផ្ទៃដីសរុបទំហំ ២៦០ ហិកតា សហគមន៍ព្រៃឈើអញ្ចាញ ផ្ទៃដីសរុបទំហំ ១២៣ ហិកតា សហគមន៍ព្រៃឈើវាលកន្សែង ផ្ទៃដីសរុបទំហំ ១ ៦២៤ហិកតា ស្ថិតនៅក្នុងខេត្តក្រចេះ។



កិច្ចប្រជុំពិភាក្សាជាមួយសហគមន៍ព្រៃឈើអូរអាចម៍កុក ស្ថិតនៅខេត្តពោធិ៍សាត់

## ២.៣-បង្កើនជីវភាព និងផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

-បានសហការជាមួយគម្រោងរេដបូកកម្ពុជា-កូរ៉េ ចុះសម្របសម្រួលក្នុងការដំឡើងសូឡាបូមទឹក មានចំណុះ ៥០០០លីត្រ ចំនួន០១កន្លែង ដល់សហគមន៍ព្រៃឈើព្រៃស្រែព្រីង និងបានផ្តល់GPSចំនួន០៦គ្រឿងដល់សហគមន៍ព្រៃឈើភូមិរំចេក សហគមន៍ព្រៃឈើព្រៃតាតី សហគមន៍ព្រៃឈើព្រៃអូរក្រញាក សហគមន៍ព្រៃឈើព្រៃអូរក្រញូង សហគមន៍ព្រៃឈើព្រៃអូរបុស្សលាវ និងសហគមន៍ព្រៃឈើព្រៃជាស់ស្គរ ផ្តល់ថវិកាសម្រាប់ការងារល្បាតព្រៃសហគមន៍ ចំនួន ១៤កន្លែង នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ





ការអនុវត្តគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋ ក្នុងសហគមន៍ព្រៃឈើក្រាំងធំ ស្ថិតនៅខេត្តពោធិ៍សាត់

-បានសហការជាមួយខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរដែនដី និងសហគមន៍ព្រៃឈើ អនុវត្តប្រព័ន្ធកសិ-រុក្ខកម្មនៃគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋ លើផ្ទៃដីសរុបទំហំ ១៦ហិកតា នៅក្នុងព្រៃសហគមន៍ចំនួន ០៨កន្លែង (២ហិកតា/សហគមន៍) ក្នុងនោះ ខេត្តកំពង់ឆ្នាំងចំនួន ០៤កន្លែង និង ខេត្តពោធិ៍សាត់ចំនួន ០៤កន្លែង

-គម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋ ក្នុងសហគមន៍ព្រៃឈើទាំង០៨កន្លែង បានផ្សព្វផ្សាយ ស្តីពីទស្សនទានស្តីពីប្រព័ន្ធកសិ-រុក្ខកម្ម បានបោះពុម្ព និងចែកផ្សាយសៀវភៅឯកសារទស្សនទាន ស្តីពីប្រព័ន្ធកសិ-រុក្ខកម្ម និងបច្ចេកទេសដាំដុះដំណាំកសិកម្មប្រចាំរដូវ បានធ្វើការដាំកូនឈើមានតម្លៃ និងឫស្សី សរុបចំនួន ៤ ៧០០ដើម និងបានចែកពូជដំណាំដល់សហគមន៍ព្រៃឈើដើម្បីធ្វើការដាំដុះនៅចន្លោះជួរកូនឈើដែលបានដាំរួច

-បានចុះផ្សព្វផ្សាយស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន០៦កន្លែង នៅខេត្តកំពង់ឆ្នាំង។





ការអនុវត្តគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋក្នុងសហគមន៍ព្រៃឈើចម្ការព្រៃស្នេហ៍ នៅខេត្តកំពង់ឆ្នាំង

## ៣-ការគ្រប់គ្រងផល អនុផលព្រៃឈើ

### ៣.១-ការចុះបញ្ជិកា និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត

បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត សរុបចំនួន១១០គ្រឿង និងយានយន្តសរុបចំនួន១៤៥គ្រឿង ជូនក្រុមហ៊ុនចំនួន០៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ០១នាក់។

### ៣.២-ការផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ

បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ០៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ០៨នាក់ មានឈើហ៊ុបមូលចំនួន ២១ ៦៥០ម៉ែត្រគ្រីគុណ ឈើអារចំនួន១ ៥២៧ម៉ែត្រគ្រីគុណ ឈើជ្រុងចំនួន៤ម៉ែត្រគ្រីគុណ កូនឈើចំនួន ២៥២២៩៥ដើម បង្គោលរបងចំនួន ៣៥ដើម បង្គោលក្រាក់ចំនួន ៤០ដើម អុសចម្រុះចំនួន ១៩០ ៥៩៧ស្ទែរ គ្រែចំនួន ៧ឈុត ទ្វារចំនួន ៤៧សន្លឹក ឫស្សីចំនួន ៩៦តោន ធ្យូងចំនួន ៣ ០០០គីឡូក្រាម និងជ័រទឹកចំនួន ៦២៨តោន។

### ៣.៣-ការធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ

បានធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ និងបានរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ០៥ក្រុមហ៊ុន គឺក្រុមហ៊ុន សល សុភា ពាណិជ្ជ ស្ថិតនៅខេត្តស្ទឹងត្រែង និងក្រុមហ៊ុន ស៊ីងបាយ អូរថេក (ខេមបូឌា) ខូអិលធីឌី ស្ថិតនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ក្រុមហ៊ុន សាន ហ៊ាង (កម្ពុជា) អាហារ័ណនីហារ័ណ ឯ.ក ស្ថិតនៅខេត្តឧត្តរមានជ័យ ក្រុមហ៊ុន ខេមបូឌា ដោន ផ្លេនថេសិនអិលធីឌី ស្ថិតនៅខេត្តព្រះវិហារ និងក្រុមហ៊ុន សុវណ្ណភូមិ វិនិយោគកសិ-ឧស្សាហកម្ម នៅខេត្តព្រះវិហារ។





ការចុះធ្វើសារពើភណ្ឌប៉ាន់ស្មានធនធានព្រៃឈើ នៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

## ៤-ការចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា

-មន្ត្រីចំនួន០៣រូបបានចូលរួមប្រជុំស្តីពីការផ្សព្វផ្សាយអំពីលក្ខខណ្ឌតម្រូវនានា សម្រាប់ការងារសរសេរគម្រោងសំណើសុំការគាំទ្រពីអង្គការ AFoCO នៅរដ្ឋបាលព្រៃឈើ

-មន្ត្រីចំនួន ០៤រូប បានចូលរួមវគ្គបណ្តុះបណ្តាលខ្លីពីចម្ងាយ ស្តីពីសារពើភណ្ឌព្រៃឈើរៀបចំដោយគម្រោង FA-JICA

-មន្ត្រីចំនួន ០១រូប បានចូលរួមកិច្ចប្រជុំលើកទី៨ របស់គណៈកម្មាធិការសហប្រតិបត្តិការព្រៃឈើកូរ៉េ-មេគង្គ តាមអនឡាញ(Zoom) នៅរាជធានីភ្នំពេញ

-មន្ត្រីចំនួន ០១រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Community-based Forest Enterprise Development (CBFED) តាមរយៈ Video Conference

-មន្ត្រីចំនួន ០៤រូប បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យបញ្ចប់ឯកសារ The State and Outlook of Agro-forestry in ASEAN) តាមរយៈ Video Conference

-មន្ត្រីចំនួន ០២រូប បានចូលរួមវគ្គសិក្ខាសិលាស្តីពី "Mapping Nature for people and plant in Cambodia" តាមរយៈOnline

-មន្ត្រីចំនួន ០៤រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិតាមរយៈប្រព័ន្ធអេឡិចត្រូនិច (Video Conference)ស្តីពីការធ្វើពាណិជ្ជកម្មព្រៃឈើប្រកបដោយនិរន្តរភាព ក្នុងតំបន់ទន្លេមេគង្គក្រោម (Regional Project on Sustainable Forest Trade in the Lower Mekong Regoin)

-មន្ត្រីចំនួន ០១រូប បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយតម្រង់ទិស ស្តីពីការអនុវត្តផែនការសកម្មភាពសម្រាប់ការងារកិច្ចការចុះសិក្សាស្រាវជ្រាវដីសមូហភាពសគមន៍ជនជាតិភាគតិច នៅខេត្តមណ្ឌលគិរី

-មន្ត្រីចំនួន ០១រូប បានចូលរួមវគ្គសិក្ខាសិលា ស្តីពីការចែករំលែកបទពិសោធន៍ការងារហាត់ការ នៅអង្គការអន្តរជាតិ តាមរយៈកម្មវិធី ZOOM Online

-មន្ត្រីចំនួន ០៦រូប បានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការបកស្រាយរូបភាពផ្កាយរណបតាមរយៈកម្មវិធី Google Earth Engine នៅភ្នំពេញថ្មី

-មន្ត្រីចំនួន ០១រូប បានចូលរួមប្រជុំគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល តាមរយៈកម្មវិធី Zoom

-មន្ត្រីចំនួន០៤រូបបានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ទៅលើសេចក្តីព្រាងនីតិវិធី និងដំណើរការបច្ចេកទេសសម្រាប់ការប្រមូលផលលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណីក្នុងសហគមន៍ព្រៃឈើ ជាមួយតំណាងអង្គការ RECOFT និង FAO តាមរយៈកម្មវិធី Zoom

-មន្ត្រីចំនួន ០២រូប បានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីព្រៃឈើអាស៊ាន(ASOF) និងកិច្ចប្រជុំក្រុមការងារជំនាញព្រៃឈើ (AWG-FPD) លើកទី២៤ តាមរយៈប្រព័ន្ធបញ្ចូលសំឡេង និងរូបភាព

-មន្ត្រីចំនួន០៤រូប បានចូលរួមកិច្ចប្រជុំស្តីពីការបំពេញ Questionnaires for Internal Ex-Post Evaluation Survey on The Project For Facilitating the Implementation of REDD+ Strategy and Policy

-មន្ត្រីចំនួន ០១រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងព្រៃតំបន់ត្រូពិច ដោយការប្រើប្រាស់ JJ-Fast Alos-2 ផ្តោតទៅលើការត្រួតពិនិត្យប្រព័ន្ធព្រៃឈើ និងបច្ចេកទេសរូបភាពផ្កាយរណប តាមរយៈកម្មវិធី Zoom

-មន្ត្រីចំនួន ០២រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Unlocking the potential of Naturalbased Solution for Climate Action and Green Recovery តាមរយៈកម្មវិធី Zoom

-មន្ត្រីចំនួន ០១រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងភ្លើងព្រៃ របស់អង្គការ AFoCO តាមរយៈប្រព័ន្ធអនឡាញ (Zoom)

-មន្ត្រីចំនួន ០៥រូប បានចូលរួមសិក្ខាសាលាស្តីពី Cultivation Comprehensive Utilization of Bamboo Resources for INBAR Member Countries តាមរយៈប្រព័ន្ធអនឡាញ (Zoom)

-មន្ត្រីចំនួន ០៥រូប បានចូលរួមសិក្ខាសាលាស្តីពី Sustainable Development and Management of Bamboo and Rattan Resources for BRI Countries តាមរយៈ អនឡាញ( Zoom)

-មន្ត្រីចំនួន ០២រូប បានចូលរួមកិច្ចប្រជុំ ស្តីពីការពិភាក្សាខ្លឹមសារសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យព្រៃឈើ តាមរយៈប្រព័ន្ធអនឡាញ (Zoom)។

# សមិទ្ធផលអភិវឌ្ឍចម្ការព្រៃដាំ និងព្រៃឯកជន

## ១-ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍

### ១.១-ការងារជីកប្រឡាយការពារតំបន់ចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

បាន និងកំពុងអនុវត្តគម្រោងជីកប្រឡាយការពារតំបន់ចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្មស្ថិតនៅក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលគម្រោងផែនការសរុបប្រវែង ៨ ០០០ម៉ែត្រ អនុវត្តបានប្រវែង ៦ ០០០ម៉ែត្រ។



ប្រឡាយដែលបានជីកនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ

### ១.២-ការងារចុះសិក្សាទីតាំងដីសម្រាប់បង្កើតស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

-បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើផ្ទៃដីទំហំ ២៦៦ ០៤៣ម៉ែត្រការ៉េ នៃស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើសំបួរមាសស្ថិតនៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង

-បានបញ្ចប់នីតិវិធី និងត្រៀមទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើផ្ទៃដីទំហំ ៤ ១៤២ ហិកតា៧៨ នៃចម្ការឈើដាំស្ថិតក្នុងស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំង

-បានចុះពិនិត្យ និងចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនលើផ្ទៃដីទំហំ ៣៥៨ហិកតា៩២៣៣

-ចុះសិក្សាទីតាំងសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើលើផ្ទៃដីសរុបទំហំ២២១០៨ហិកតា០៦៧៦

-បានចុះសិក្សាទីតាំងសម្រាប់បង្កើតសួនរុក្ខជាតិ លើផ្ទៃដីទំហំ៤៩ហិកតា១៩ស្ថិតនៅឃុំស្តេចគង់ខាងត្បូង។



ទីតាំងបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនៅសួនអាពាហ៍ពិពាហ៍ស្រុកភ្នំក្រវាញ និងស្រុកក្រគរ ខេត្តពោធិ៍សាត់

### ១.៣-ការងារចុះពិនិត្យ តាមដាន និងវាយតម្លៃស្ថានភាពចម្ការឈើ

-ក្រុមការងារបានចុះពិនិត្យស្រាវជ្រាវ និងទប់ស្កាត់ការកាប់រានឈូសឆាយរំលោភដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើមាសហែក-តាសួស ក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង

-បានប្រជុំពិភាក្សា និងចុះសម្របសម្រួលការស្នើសុំអន្តរាគមន៍លើបញ្ហាដីធ្លីដែលកើតមានឡើងក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី ដែលស្ថិតនៅឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ និងឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងបានពង្រឹងការអនុវត្តផែនការមេតាមកិច្ចសន្យាពន្លឿនការចុះបញ្ជីដី ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើរស្មីសាមគ្គីឱ្យបានឆាប់រហ័ស។

## ២-ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម

### ២.១-ការងារដាំឈើជាចម្ការថ្មី

បានដាំឈើសរុបទំហំ១៣០ហិកតា នៅក្នុងស្ថានីយចំនួន២ទីតាំងរួមមាន ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ ទំហំ៨០ហិកតា និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើម្សៅក្រដាសហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំង ទំហំ៥០ហិកតា។



ចម្ការឈើដាំនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ម្រៀក្រដាសហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំង

**២.២-ការងារថែទាំចម្ការឈើចាស់ឆ្នាំទី១ ដល់ឆ្នាំទី៥**

បាន និងកំពុងថែទាំចម្ការឈើ សរុប ៨២២ហិកតា ក្នុងនោះចម្ការពូជឈើ៩៤ហិកតា ឡូត៍ បង្ហាញកសិ-រុក្ខកម្ម ៤៤ហិកតា ចម្ការឈើដាំទំហំ៦៥៤ហិកតា និងចម្ការរុក្ខទិវា៩កក្កដា សរុបទំហំ ៣០ហិកតា ស្ថិតក្នុងខេត្តកំពតកណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ ។

**២.៣-ការងារបណ្តុះកូនឈើសម្រាប់ចែកចាយដល់កសិករដាំអាស្រ័យផល**

បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ១៨៣ ១២២ដើម និងបានចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលចំនួន ៣៦០ ៥៤៥ដើម ដែលក្នុងនោះបណ្តុះកូនឈើដោយខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ១៦៩ ៤៥០ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦(ថវិការដ្ឋ) បណ្តុះកូនឈើបានចំនួន ១៩១ ០៩៥ដើម។



**២.៤-ការងារបង្កើតចម្ការពូជឈើក្នុងស្រុក**

បានដាំប្រភេទឈើទាល កកោះ និងធ្នង់ ជាចម្ការពូជក្នុងស្រុកលើផ្ទៃដី ទំហំ១០ហិកតាសម្រេចបាន១០០% នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ស្ថិតក្នុងភូមិសាស្រ្ត ស្រុកសន្ទុក ខេត្តកំពង់ធំ។



**២.៥-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្តុះកូនឈើ**

បានរៀបចំ និងសាងសង់ថ្នាលបណ្តុះកូនឈើចំនួន ០១ស្ថិតនៅក្នុងភូមិសាស្រ្តភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដើម្បីបណ្តុះកូនឈើចែកជូនប្រជាពលរដ្ឋ សម្រេចបានចំនួន១០០% (ថ្នាលមានគម្របស៊ែរទំហំ ១០០០ម² ថ្នាលចំហមិនមានគម្របទំហំ ២០០០ម² ប្រព័ន្ធស្រោចស្រពចំនួន០១ឈុត រទេះរុញចំនួន០១គ្រឿង ម៉ូទ័រ ក្លោងទ្វារ និងស្លាកឈ្មោះធ្វើអំពីដែកលាបថ្នាំ)។




**២.៦-ការងារពិសោធន៍ការបណ្តុះអាកាស្យា (Acacia hybrid) និងប្រេងខ្យល់**

ការងារពិសោធន៍ការបណ្តុះអាកាស្យា (Acacia hybrid) និងប្រេងខ្យល់តាមរយៈការកាត់ត្រួយពីដើមមេ